**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២០៤៣ ព.ណ.ក.ស.ប

ថ្ងៃសុក្រ ៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

**ជម្រាបមក**

**លោក/លោកស្រីប្រធាន ក្រុមហ៊ុន ចូតាន់ (ខេមបូឌា) អិលធីឌី**

**កម្មវត្ថុ:** ការបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលថ្នាំលាប ថ្នាំវ៉ានីស ថ្នាំលាបដែក ថ្នាំលាបការពារគីង សម្រាប់ទូកកប៉ាល់ និងសំណង់ខួងប្រេង ផលិតផលការពារច្រេះ និងរក្សាសភាពដើមរបស់ឈើ ថ្នាំលាប (បៀក) (ទម្រង់ជាថ្នាំលាប) សម្រាប់ទូកកប៉ាល់ និងសំណង់ខួងប្រេង ម្សៅវ៉ានីស ម្សៅវ៉ានីសសម្រាប់ការពារ និងកែលម្អរផ្ទៃនៃផលិត ផលធ្វើពីដែក ប្លាស្ទិច ឈើកិន ឬឈើម៉ាក JOTUN ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ចូតាន់ (ខេមបូឌា) អិលធីឌី**។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ចូតាន់ (ខេមបូឌា) អិលធីឌី** ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០
- លិខិតកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខលេខ ២៨៥៧ ព.ណ កសប ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន JOTUN A/S ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៣៩៥០៤/១១ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពបន្តសុពលភាពកត់ត្រា ទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលថ្នាំលាប ថ្នាំវ៉ានីស ថ្នាំលាបដែក ថ្នាំលាបការពារគីង សម្រាប់ទូកកប៉ាល់ និងសំណង់ខួងប្រេង ផលិតផលការពារច្រេះ និងរក្សាសភាពដើមរបស់ឈើ ថ្នាំលាប (បៀក) (ទម្រង់ជាថ្នាំលាប) សម្រាប់ទូកកប៉ាល់ និងសំណង់ខួងប្រេង ម្សៅវ៉ានីស ម្សៅវ៉ានីសសម្រាប់ការពារ និងកែលម្អរផ្ទៃនៃផលិត ផលធ្វើពីដែក ប្លាស្ទិច ឈើកិន ឬឈើពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ចូតាន់ (ខេមបូឌា) អិលធីឌី** ដែលទទួលបានពីក្រុមហ៊ុន JOTUN A/S ដូចមានចែងក្នុងលិខិតប្រគល់ សិទ្ធិនាំចូលផ្តាច់មុខរបស់ម្ចាស់ម៉ាកដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតបន្តសុពលភាពកត់ត្រា និងតម្កល់សិទ្ធផ្តាច់មុខនេះ មានសុពលភាពចាប់ពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ ដល់ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២១ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន JOTUN A/S ដែលជាម្ចាស់ម៉ាក។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

*<u>ចម្លងជូន:</u>*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ស ខេង*
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469